


**សង្ខេបអំពីគម្រោង**

# រដ្ឋាភិបាលកម្ពុជា ៖ កម្មវិធីភាពជាដៃគូសម្រាប់កិច្ចការពារកុមារ (3PC)

## ដំណាក់កាលទី៣ (២០១៦-២០១៨)

**សេចក្តីថ្លែងពី ឯកឧត្តម វង សូត**
**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**

“ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង សអយ) ប្តេជ្ញាការពារកុមារក្នុងប្រទេសកម្ពុជា និងផ្តល់សេវាសុខុមាលភាពសង្គមជូនដល់កុមាររងគ្រោះ និង គ្រួសាររបស់ពួកគេ តាមរយៈប្រព័ន្ធការពារកុមារមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង មានប្រសិទ្ធភាព។ ក្នុងនាមជារដ្ឋមន្ត្រី ខ្ញុំសូមធ្វើការចែករំលែកអំពីការងាររបស់យើងទាក់ទងនឹងកិច្ចការពារកុមារកម្ពុជា។ យើងទទួលស្គាល់ថាបញ្ហាប្រឈមផ្នែកការពារកុមារ មានវិសាលភាពធំ ហើយប្រព័ន្ធ និង ធនធានដែលយើងមាន នៅមានកម្រិត។ ខ្ញុំសូមឆ្លៀតយកឱកាសនេះថ្លែងអំណរគុណដល់គ្រប់បណ្តាដៃគូទាំងអស់ រាប់បញ្ចូលទាំង USAID ដែលជាដៃគូហិរញ្ញវត្ថុរបស់យើងផងដែរ។ ខ្ញុំសង្ឃឹមថា សេចក្តីសង្ខេបអំពីកម្មវិធី 3PC នេះនឹងមានសារៈប្រយោជន៍ក្នុងការរៀនសូត្រអំពីសមិទ្ធិផលរបស់យើងដែលសម្រេចបាន និង ផែនការសម្រាប់រយៈពេល៣ឆ្នាំបន្ទាប់។ ”

**ឯកឧត្តម តូច ចាន់នី អគ្គនាយក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**

"កុមារក្នុងប្រទេសកម្ពុជាកំពុងទទួលបានកិច្ចការពារកាន់តែច្រើនឡើងជាលំដាប់ តាមរយៈបទប្បញ្ញត្តិ និងសេវាដែលមាន លក្ខណៈប្រសើរជាងមុន ជាពិសេសនៅក្នុងវិស័យការថែទាំជំនួស។ បើទោះជាដូច្នេះក្តី កុមារកម្ពុជាប្រឈមនឹងហានិភ័យជាច្រើន ដូចជាអំពើហិង្សា និង ការទុកដាក់កុមារនៅក្នុងមណ្ឌលថែទាំកុមារ ដែលធ្វើឱ្យពួកគេមានការប្រឈមកាន់តែខ្លាំងឡើងទៅនឹង អំពើហិង្សា ការកេងប្រវ័ញ្ច និង ការមិនអើពើ។ ក្រសួងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រីករាយក្នុងការបោះជំហានចូលទៅក្នុងដំណាក់កាលទីបី នៃភាពជាដៃគូនេះ ដើម្បីឱ្យកុមារកាន់តែច្រើន អាចមានលទ្ធភាព ទទួលបានបរិយាកាសប្រកបដោយសុវត្ថិភាព និង បរិយាកាសដែលផ្តល់កិច្ចការពារ។"

# ការថែទាំដោយឪពុកម្តាយធម៌សម្រាប់សូរិយា

*សាច់រឿងនេះបង្ហាញអំពីរបៀបដែលដៃគូកម្មវិធី 3PC សហការគ្នា។ AHC (ដៃគូបណ្តាញ) ជាអ្នកធ្វើការបញ្ជូន ដោយឡែកចំពោះការទុកដាក់ជាមួយ គ្រួសារធម៌ គឺ កល្យាណមិត្ត (ដៃគូអនុវត្ត) ជាអ្នកគ្រប់គ្រង ដោយការទុកដាក់ នេះបានទទួលការអនុម័តយល់ព្រមពីរដ្ឋាភិបាល និង អង្គការយូនីសេហ្វ (ដោយមានវិភាគទានពី USAID) ជាអ្នកផ្តល់កិច្ចគាំទ្របច្ចេកទេស និង ហិរញ្ញវត្ថុ។*



©UNICEF Cambodia/2016/Patricia Chourio

*លោកស្រី សារ៉េត និង សូរិយា មានការផ្សាភ្ជាប់ទំនាក់ទំនងមួយដ៏ពិសេស។*

សូរិយាដែលមានអាយុ៣ឆ្នាំ (បានប្តូរឈ្មោះ) បានកើតមកដោយមាន ជំងឺពិការចលនា និង ដោយសារតែឪពុកម្តាយខ្វះទំនុកចិត្តចំពោះ សមត្ថភាពរបស់ពួកគេក្នុងការថែទាំកូនពួកគេបានបោះបង់សូរិយា នៅឯមន្ទីរពេទ្យកុមារអង្គរ នៅពេលដែលសូរិយាមានអាយុប្រមាណ ៩ខែ។ នៅក្នុងគម្រោងថ្មីដំបូងបង្អស់របស់ខ្លួន អង្គការកល្យាណមិត្ត (ដៃគូរបស់កម្មវិធី 3PC) និង AHC(ដៃគូបណ្តាញរបស់កម្មវិធី 3PC) បានអនុវត្តសាកល្បងការទុកដាក់ថែទាំជំនួសចំពោះកុមារ ដូចជា សូរិយា ជំនួសឱ្យការបញ្ជូនពួកគេទៅមណ្ឌលថែទាំ ហើយស្របពេលជាមួយគ្នានោះក៏រៀបចំផែនការទុកដាក់ពួកគេរយៈពេលវែងផងដែរ។ បើទោះបីជាការថែទាំសូរិយា ជួនកាលមានការលំបាកក៏ដោយ ប៉ុន្តែ លោកស្រី សារ៉េត ដែលជាម្តាយចិញ្ចឹមរបស់សូរិយា អស់រយៈពេល ជិត២ឆ្នាំកន្លងមក បានប្រាប់ឱ្យដឹងថា កិច្ចខិតខំរបស់លោកស្រីមានតម្លៃ ៖ "ជួនកាលខ្ញុំហៅឈ្មោះរបស់គាត់ពីបន្ទប់មួយផ្សេងទៀត ហើយគាត់ស្គាល់សម្លេងរបស់ខ្ញុំ ក៏ងើបក្បាលឡើងស្វែងរកខ្ញុំ"។ លោកស្រីបានបន្ថែមទៀតថា "វាមានតម្លៃខ្លាំងណាស់ ហើយនៅពេលដែលខ្ញុំឃើញគាត់ម្តងៗ បេះដូងរបស់ខ្ញុំពោរពេញទៅដោយសេចក្តីរីករាយ"។

## ភស្តុតាងនៃភាពជោគជ័យ

ការវាយតម្លៃឯករាជ្យមួយក្នុងឆ្នាំ២០១៥ ដែលគាំទ្រដោយ USAIDបានរកឃើញថា កម្មវិធី 3PC សម្រេចបានផលប៉ះពាល់គួរឱ្យកត់សម្គាល់នៅគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធថែទាំជំនួសក្នុងប្រទេសកម្ពុជា ដូចមានភស្តុតាងបញ្ជាក់តាមរយៈក្របខ័ណ្ឌច្បាប់ដ៏រឹងមាំ និង ការផ្តល់សេវាដោយផ្ទាល់ ជូនដល់កុមារ និងគ្រួសារងាយរងគ្រោះជាច្រើនគួរឱ្យកត់សម្គាល់ (កុមារចំនួន ៣១.៥៨៧នាក់ ក្នុងឆ្នាំ២០១៥)។ គម្រោងនេះបានពង្រីកសេវាថែទាំជំនួសតាមគ្រួសារ និង សហគមន៍ (រាប់បញ្ចូលការអភិវឌ្ឍន៍ និង ការកែលម្អកម្មវិធីថែទាំ ដោយឪពុកម្តាយធម៌ ដែលមិនទាន់បានអនុវត្តទូលំទូលាយក្នុងប្រទេសកម្ពុជា) ព្រមទាំងបានធ្វើសមាហរណកម្មកុមារពីមណ្ឌលថែទាំកុមារ ទៅក្នុងការថែទាំតាមគ្រួសារ និងសហគមន៍។ ដោយមានកិច្ចគាំទ្រពីអង្គការយូនីសេហ្វ ក្រសួង សអយ បានធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារ បិទមណ្ឌលថែទាំកុមារទាំងឡាយណាដែលពុំមានលក្ខខណ្ឌស្របទៅតាមបទដ្ឋានកំណត់ និង កំណត់ទីតាំងចំនួនមណ្ឌល និងកុមារដែលរស់នៅក្នុងមណ្ឌលទូទាំងប្រទេស។

# ការធ្វើសមាហរណកម្មកុមារពី "មណ្ឌលកុមារកំព្រា"

*សាច់រឿងនេះឆ្លុះបញ្ចាំងអំពីស្មារតីនៃភាពជាដៃគូរបស់កម្មវិធី 3PC ដែលយើងក្នុងនាមរដ្ឋាភិបាល ដើរតួនាទីអនុវត្តគោលនយោបាយ និងដៃគូអង្គការសង្គមស៊ីវិល ធ្វើការងារជាមួយបុគ្គលិកសង្គមកិច្ចរបស់រដ្ឋាភិបាល ដើម្បីផ្តល់សេវាជាក់ស្តែងនៅមូលដ្ឋាន។*

ក្រោយពេលដែលឪពុករបស់គាត់បានស្លាប់ ចិត្ត ត្រូវបានម្តាយបញ្ជូនឱ្យទៅរស់នៅក្នុង "មណ្ឌលកុមារកំព្រា" មួយក្នុងខេត្តសៀមរាប ដោយម្តាយរបស់គាត់ជឿថា គាត់នឹងទទួលបានអាហារ ជម្រក និង ការអប់រំល្អ ព្រមទាំងមានឱកាសរៀនភាសាអង់គ្លេសពីជនបរទេសផងដែរ។ ការធ្វើអធិការកិច្ចមួយរបស់រដ្ឋាភិបាលក្នុងឆ្នាំ២០១៤ បានរកឃើញថា មណ្ឌលកុមារកំព្រានេះពុំបានផ្តល់សេវាស្របទៅតាមបទដ្ឋាន និង មិនបានផ្តល់អាហារ ព្រមទាំង ការថែទាំនានាដែលចាំបាច់ឡើយ។ ក្រោយពេលដែលមណ្ឌលនេះត្រូវបានបិទ អង្គការយូនីសេហ្វ និង ដៃគូរបស់ខ្លួន បានចាប់ផ្តើមធ្វើការងារគ្រប់គ្រងករណីរបស់ ចិត្ត និង កុមារចំនួន៣៥នាក់ដទៃទៀត ដែលត្រូវបានបង្រួបបង្រួមជាមួយគ្រួសាររបស់ពួកគេនៅពេលក្រោយមកទៀត។ ឥឡូវនេះ ចិត្ត មានភាពសប្បាយរីករាយដោយបានចុះឈ្មោះចូលរៀននៅឯសាលាមួយក្នុងមូលដ្ឋាន។ ប៉ុន្តែ ការធ្វើសមាហរណកម្មមានលក្ខណៈលើកពីការដែល គ្រាន់តែធ្វើការបង្រួបបង្រួមជាមួយគ្រួសារ ដោយវាទាមទារឱ្យមានការផ្តល់កិច្ចគាំទ្រផ្នែកសង្គម និង ចិត្តសង្គមរយៈពេលវែង។ សេវាទាំងនេះត្រូវបានផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ។ ម្តាយរបស់ ចិត្ត បាននិយាយថា មណ្ឌលថែទាំកុមារបង្កឱ្យមានគ្រោះថ្នាក់ច្រើនជាងការផ្តល់ផលល្អចំពោះគ្រួសារ។ គាត់បាននិយាយបន្ថែមទៀតថា "ខ្ញុំនឹងមិនបញ្ជូនកូនប្រុសរបស់ខ្ញុំឱ្យទៅរស់នៅមណ្ឌលថែទាំកុមារទៀតឡើយ។ ខ្ញុំនឹងឈប់ជឿអ្នកដែលបាននិយាយបញ្ចុះបញ្ចូលខ្ញុំឱ្យបញ្ជូនកូនរបស់ខ្ញុំទៅរស់នៅក្នុងមណ្ឌលបែបនេះ អាស្រ័យដោយ មណ្ឌលបែបនេះបានបង្កគ្រោះថ្នាក់ជាច្រើនមកលើរូបខ្ញុំផ្ទាល់ និងកូនប្រុសរបស់ខ្ញុំ។"

## គោលដៅ

ដើម្បីពង្រឹងប្រព័ន្ធសម្រាប់កិច្ចការពារកុមារក្នុងប្រទេសកម្ពុជា សំដៅបង្ការ និង ឆ្លើយតបទៅនឹងអំពើហិង្សា ការកេងប្រវ័ញ្ច ការរំលោភបំពាន និង ការបំបែកកុមារពីគ្រួសារដោយមិនចាំបាច់។

## គោលបំណង

ដើម្បីផ្តល់ជំនួយភ្លាមៗ និង ជំនួយរយៈពេលវែងជូនដល់កុមារដែលមានហានិភ័យ ឬ ប្រឈមទៅនឹងអំពើហិង្សា និង ការបំបែកពីគ្រួសារដោយមិនចាំបាច់ ក្នុងគោលបំណង រួមចំណែកដល់គោលដៅកាត់បន្ថយអំពើហិង្សាលើកុមារ ឱ្យបាន៣០% និង ការបញ្ជូនកុមារដែលកំពុងរស់នៅក្នុងមណ្ឌល ចំនួន៣០% ឱ្យវិលត្រឡប់ទៅគ្រួសាររបស់ពួកគេវិញប្រកបដោយសុវត្ថិភាព ត្រឹមឆ្នាំ ២០១៨។

## យុទ្ធសាស្ត្រ

១. ការកសាងប្រព័ន្ធ (សមត្ថភាពនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ)

២. កិច្ចសហការលក្ខណៈជាប្រព័ន្ធ រវាងរាជរដ្ឋាភិបាលកម្ពុជា អង្គការយូនីសេហ្វ និង វិស័យអង្គការមិនមែនរដ្ឋាភិបាល (ការសម្របសម្រួល ការតភ្ជាប់បណ្តាញ និង ការបញ្ជូន, ដៃគូរបស់កម្មវិធី 3PC មានជំនាញឯកទេសផ្សេងៗគ្នា និង បំពេញឱ្យគ្នាទៅវិញទៅមក, គំនិតផ្តួចផ្តើមដែលទទួលបាន ជោគជ័យរបស់ដៃគូមួយ ត្រូវបានដៃគូដទៃទៀតចម្លងយកគំរូ ទៅអនុវត្តតាម)។

៣. ពង្រឹងសមត្ថភាពសហគមន៍ (យុទ្ធនាការណ៍ផ្លាស់ប្តូរការប្រព្រឹត្ត ដើម្បីលើកកម្ពស់ទម្លាប់ការពារកុមារបែបវិជ្ជមាននៅកម្រិតសហគមន៍)។

**ឈ្មោះកម្មវិធី** ៖ កម្មវិធីភាពជាដៃគូសម្រាប់កិច្ចការពារកុមារ (3PC) ដំណាក់កាលទី៣

**រយៈពេលគម្រោង** ៖ ខែឧសភា ឆ្នាំ២០១៦ - ខែធ្នូ ឆ្នាំ២០១៨

**ទីតាំង** ៖ ខេត្តបាត់ដំបង ខេត្តកណ្តាល រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តព្រៃវែង

**គោលដៅសំខាន់ៗត្រឹមឆ្នាំ២០១៨** ៖

- កុមារចំនួន ២៤.០០០នាក់ដែលមានហានិភ័យ ឬប្រឈមនឹងអំពើហិង្សា ទទួលបានសេវាបង្ការ និង សេវាការពារកុមារដែលផ្តល់ការឆ្លើយតប
- កុមារចំនួន ៣.៥០០នាក់ ពីមណ្ឌលថែទាំ ត្រូវបានធ្វើសមាហរណកម្មទៅក្នុងការ ថែទាំតាមគ្រួសារ និង សហគមន៍វិញ
- ថ្នាក់បំប៉ន/ការអប់រំក្រៅប្រព័ន្ធ បានផ្តល់ជូនដល់កុមារចំនួន ២.៥០០នាក់
- កុមារចំនួន ២.១៥០ ត្រូវបាន ធ្វើសមាហរណកម្មទៅក្នុងសាលារដ្ឋវិញ
- យុទ្ធនាការណ៍អន្តរជាតិស្តីពីផលប៉ះពាល់ដ៏គ្រោះថ្នាក់នៃទេសចរណ៍មណ្ឌលកុមារកំព្រា និង "ការងារស្ម័គ្រចិត្ត" នៅតាមមណ្ឌលកុមារកំព្រា បានផ្សព្វផ្សាយជូនប្រជាពលរដ្ឋចំនួន១៣០.០០០នាក់
- យុទ្ធនាការណ៍ស្តីពីការផ្លាស់ ប្តូរការប្រព្រឹត្តដើម្បីបង្ការ និង ឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ និង ការបំបែកកុមារពីគ្រួសារ បានផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋចំនួន ១៩៨.០០០នាក់។

# ការជួយដល់យុវជនងាយរងគ្រោះ ដើម្បីស្វែងរកក្ដីសង្ឃឹមម្ដងទៀត



©Mith Samlanh/Cambodia/2016

*យុវជនវ័យក្មេងនៅក្នុងថ្នាក់ចំអិនអាហារនៅឯមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់អង្គការមិត្តសំឡាញ់ក្នុងរាជធានីភ្នំពេញ។*

បូណា (បានប្ដូរឈ្មោះ) ត្រូវបានបង្ខំឱ្យរត់ចេញពីគ្រួសាររបស់គាត់ក្នុងខេត្តស្ទឹងត្រែងកាលពី៣ឆ្នាំមុន ដោយសារតែអំពើហិង្សាកើតឡើងញឹកញាប់ក្នុងគ្រួសារ។ ក្រោយពេលរស់នៅក្នុងជីវិតមួយដ៏លំបាកវេទនា ដោយការដើរសុំទានតាមចិញ្ចើមថ្នល់ក្នុងរាជធានីភ្នំពេញ នៅទីបំផុតគាត់ក៏ត្រូវបានអង្គការមិត្តសំឡាញ់ជួយសង្គ្រោះ។

"ជីវិតមានការលំបាកជាងការដែលខ្ញុំបានរំពឹងទុក.... ប៉ុន្ដែ ជីវិតរបស់ខ្ញុំបានប្រែប្រួលម្ដងទៀត នៅពេលដែលខ្ញុំបានជួបកុមារាម្នាក់ដែលមានអាយុច្រើនជាងខ្ញុំ និង បាននាំខ្ញុំទៅអង្គការមិត្តសំឡាញ់ ដែលអង្គការនេះផ្ដល់សេវាដើម្បីជួយដល់កុមារតាមចិញ្ចើមថ្នល់ដូចជាខ្ញុំ ឱ្យមានភាពឯករាជ្យ។"

បូណាបានបញ្ចប់វគ្គចំអិនអាហាររបស់គាត់ ក្នុងខែមេសា ឆ្នាំ២០១៦ ហើយបច្ចុប្បន្ន គាត់កំពុងបម្រើការងារជាចុងភៅនៅក្នុងភោជនីយដ្ឋានមួយក្នុងរាជធានីភ្នំពេញ។ ឥឡូវនេះ គាត់អាចទ្រទ្រង់ខ្លួនឯង និងគ្រួសាររបស់គាត់បាន។

## អភិក្រមកម្មវិធី 3PC

អភិក្រមកម្មវិធីជារួម គឺដើម្បីកំណត់រកកុមារម្នាក់ មុនពេលដែលកុមារនោះទទួលរងគ្រោះថ្នាក់ និង បន្ដផ្ដល់ការគាំទ្រ និងធ្វើសមាហរណកម្មកុមារ ក្នុងករណីដែលកុមារកំពុងរងគ្រោះថ្នាក់។ ចំនុចចាប់ផ្ដើមសម្រាប់ការផ្ដល់កិច្ចគាំទ្រ អាចធ្វើឡើងនៅកម្រិតណាមួយក៏បាន។ សូមមើលរូបភាពទី១។

### រូបភាពទី១ ៖ អភិក្រមកម្មវិធី 3PC

កុមារ/គ្រួសារដែលមានហានិភ័យ ឬ ប្រឈមទៅនឹងហានិភ័យខាងក្រោម ត្រូវបានផ្ដល់អាទិភាព ៖

- អំពើហិង្សា (ការរំលោភ បំពាន ការកេងប្រវ័ញ្ច និង ការមិនអើពើ)
- កុមារនៅក្នុងមណ្ឌល
- កុមាររស់នៅតាមចិញ្ចើមថ្នល់
- មេរោគអេដស៍/ជំងឺអេដស៍
- ពិការភាព
- ការប្រើប្រាស់បំពានគ្រឿងញៀន និងគ្រឿងស្រវឹង
- ភាពក្រីក្រ/ការមិនសូវទទួលបានការយកចិត្តទុកដាក់
- កុមារទំនាស់នឹងច្បាប់
- កុមារនៅក្រៅសាលារៀន



## សេវាបង្ការ និង ឆ្លើយតប

ដោយទទួលស្គាល់ថា ភាពងាយរងគ្រោះមានលក្ខណៈពហុវិស័យ ដូច្នេះ កម្មវិធី 3PCបានធ្វើប្រតិបត្តិការសេវាគ្រប់ជ្រុងជ្រោយ ដើម្បីធានាថា កុមារ និងគ្រួសាររបស់ពួកគេ អាចរួចផុតពីអន្ទាក់នៃភាពងាយរងគ្រោះ។

- ការកំណត់រកសហគមន៍ យន្តការឃ្លាំមើល និងយន្តការបញ្ជូន
  - ការចុះផ្សព្វផ្សាយតាមសហគមន៍ រាប់បញ្ចូល ការចុះធ្វើទស្សនកិច្ចទៅកាន់តំបន់ដែលមាន កុមារងាយរងគ្រោះច្រើន។
  - បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ (បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ចំនួន៧បានទទួលការហៅទូរស័ព្ទចូលជាង ២.០០០ លើក ជារៀងរាល់ឆ្នាំ)
  - បណ្តាញការពារកុមារតាមសហគមន៍ (សមាជិកបណ្តាញសុវត្ថិភាពកុមារតាម សហគមន៍ និង បុគ្គលិកផ្សព្វផ្សាយជាង ៥.០០០នាក់ ព្រមទាំងភ្នាក់ងារមិត្តអប់រំមិត្ត ជាង ៤០០នាក់)
- ការបង្កើតប្រាក់ចំណូល (ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការហាត់ការងារ និង ការទុកដាក់ឱ្យចូលបម្រើការងារ សកម្មភាពបង្កើតប្រាក់ចំណូល)
- ការផ្តល់សេចក្តីត្រូវការមូលដ្ឋាន (ឱសថ អាហារ ជម្រក)
- ការអប់រំ (ការអប់រំក្រៅប្រព័ន្ធ ការអប់រំបំប៉នបន្ថែម និងសមាហរណកម្មទៅក្នុងការអប់រំក្នុងប្រព័ន្ធ)
- ការផ្តល់ប្រឹក្សា/កិច្ចគាំទ្រចិត្តសង្គម
- កិច្ចគាំទ្រចំពោះការចិញ្ចឹមកូនបែបវិជ្ជមាន សកម្មភាពរវាងឪពុកម្តាយ និងកូន
- ការបង្រួបបង្រួមគ្រួសារ
- ព័ត៌មានអំពីបំណិនជីវិត
- មណ្ឌលសំចត និង មណ្ឌលសេវាគ្រប់ជ្រុងជ្រោយ
- ការបង្កើតក្រុមជួយខ្លួនឯង ចំពោះការប្រើប្រាស់បំពានគ្រឿងស្រវឹង អំពើហិង្សាក្នុងគ្រួសារ
- ផ្ទះសំចត ៖ បច្ចុប្បន្ន មានផ្ទះសំចតចំនួន៦ កំពុងមានប្រតិបត្តិការ
- ការថែទាំជំនួស ៖ ការថែទាំដោយឪពុកម្តាយចិញ្ចឹម ការថែទាំដោយញាតិ ការថែទាំជាក្រុមតាមផ្ទះ ការរៀបចំរស់នៅដោយឯករាជ្យ

## ដៃគូ


©UNICEF/Cambodia/2016/Friends-International

*អ្នកចូលរួមនៅក្នុងពិធីប្រកាសផ្សព្វផ្សាយកម្មវិធី 3PC ដំណាក់កាលទី៣*

កម្មវិធី 3PC ត្រូវបានអនុវត្តតាមរយៈភាពជាដៃគូត្រីភាគី រវាងក្រសួង សអយ អង្គការយូនីសេហ្វ និង អង្គការ Friends-International (FI)។ បន្ថែមពីនេះទៀត អង្គការ FI បានធ្វើការសម្របសម្រួលបណ្តាញអង្គការសង្គមស៊ីវិលចំនួន៩បន្ថែមទៀត (ដៃគូអនុវត្ត) ដើម្បីអនុវត្តសកម្មភាពនៅថ្នាក់មូលដ្ឋាន។ បណ្តាញអង្គការសង្គមស៊ីវិលទាំង៩នេះ បានធ្វើការប្រាស្រ័យទាក់ទងជាមួយអង្គការសហគមន៍ចំនួន៤០ (បណ្តាញរបស់ដៃគូ) ដើម្បីផ្តល់សេវា។ បន្ថែមពីនេះទៀត ក៏មានដៃគូបច្ចេកទេសចំនួន៦ ដែលផ្តល់សេវាឯកទេសក្រោមមូលដ្ឋាននៃកិច្ចសន្យាផងដែរ។

### រូបភាពទី២ ៖ តួនាទីរបស់ដៃគូថ្នាក់ជាតិ

| ក្រសួង សអយ | អង្គការយូនីសេហ្វ | អង្គការ Friends-International |
|---|---|---|
| • ផ្តល់មគ្គុទ្ទេសក៍ណែនាំអំពីការរៀបចំផែនការការត្រួតពិនិត្យ និងការអនុវត្តន៍ទិសដៅកម្មវិធីទាំងមូល<br>• សម្របសម្រួលដៃគូកម្មវិធី 3PC ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងទីភ្នាក់ងាររដ្ឋាភិបាលដទៃទៀត<br>• ដើម្បីដឹកនាំការអភិវឌ្ឍន៍ប្រព័ន្ធ និងនីតិវិធីរបស់រដ្ឋាភិបាល | • ប្រើប្រាស់ធនធាន និងសហការផ្តល់មូលនិធិគាំទ្រដល់កម្មវិធី 3PC ដំណាក់កាលទី៣<br>• ផ្តល់ជំនួយបច្ចេកទេសដោយផ្តោតលើការស្វែងរកការគាំទ្រ ការបង្កើតចំណេះដឹង ការត្រួតពិនិត្យ និង ការវាយតម្លៃ ការគ្រប់គ្រងទិន្នន័យ ការចងក្រងឯកសារ និង ការត្រួតពិនិត្យឡើងវិញទៅលើផ្នែកបច្ចេកទេស<br>• ដើម្បីប្រាស្រ័យទាក់ទងជាមួយម្ចាស់ជំនួយ | • សម្របសម្រួលជាមួយដៃគូអនុវត្តដើម្បីឱ្យការអនុវត្តមានប្រសិទ្ធភាពនិងការធានាគុណភាពចំពោះកម្មវិធីនៅថ្នាក់មូលដ្ឋាន<br>• ផ្តល់ជំនួយបច្ចេកទេសជូនដៃគូអនុវត្តចំពោះរាល់គ្រប់ទិដ្ឋភាពទាំងអស់នៃកម្មវិធី<br>• ផ្ទៀងផ្ទាត់ទិន្នន័យ និង ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ |

### រូបភាពទី៣ ៖ ការគ្របដណ្តប់ភូមិសាស្ត្ររបស់ដៃគូអនុវត្តន៍កម្មវិធី 3PC




# ការជ្រើសរើសដៃគូ

ការជ្រើសរើសដៃគូអនុវត្ត និងដៃគូបច្ចេកទេស ត្រូវបានធ្វើឡើងដោយអង្គការ FI និងមានការអនុម័តយល់ព្រមពីអង្គការយូនីសេហ្វ និង ក្រសួង សអយ។ ដៃគូថ្មីៗបន្ថែមទៀត អាចចូលរួមកម្មវិធី 3PC ដំណាក់កាលទី៣បាន ប្រសិនបើកម្មវិធីរបស់ពួកគេ ត្រូវបានចាត់ទុកថាមានភាពពាក់ព័ន្ធ និង មានសារៈប្រយោជន៍ ក្នុងការឈោងចាប់គោលដៅ រំពឹងទុកសម្រាប់កម្មវិធី 3PC ដំណាក់កាលទី៣។

# ការត្រួតពិនិត្យ និងវាយតម្លៃ

បេសកកម្មត្រួតពិនិត្យរួមគ្នាតាមមូលដ្ឋានប្រចាំឆមាស និង កិច្ចប្រជុំត្រួតពិនិត្យប្រចាំត្រីមាស ត្រូវបានធ្វើឡើងដោយក្រសួងសអយ និង អង្គការយូនីសេហ្វ និង អង្គការ Friends International ទៅលើរាល់ដៃគូទាំងអស់នៅក្នុងខេត្តអាទិភាពនីមួយៗនៃខេត្តអាទិភាពទាំង៥ ដើម្បីពិភាក្សាអំពីវឌ្ឍនភាព ដោះស្រាយបញ្ហារាំងស្ទះ និង ផ្តល់ធាតុចូលបន្ថែមទៀតទៅក្នុងកម្មវិធី។ ការត្រួតពិនិត្យឡើងវិញទៅលើឯកសារករណី និង ការចុះសួរសុខទុក្ខអ្នកទទួលផល ក៏ត្រូវបានធ្វើឡើងផងដែរ។

អនុសាសន៍ដែលទទួលបានពីការវាយតម្លៃឯករាជ្យឆ្នាំ២០១៥ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធី 3PCដំណាក់កាលទី៣ ដើម្បីពង្រឹងគម្រោងនេះ។ ជាពិសេស អនុសាសន៍ទាំងនេះ រួមមានការពង្រឹងការថែទាំដោយឪពុកម្តាយធម៌ ការអនុម័តទៅលើក្របខ័ណ្ឌច្បាប់ និង សេវានានា ការកែលម្អប្រព័ន្ធត្រួតពិនិត្យរបស់ដៃគូកម្មវិធី 3PCការអនុវត្តន៍បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារឱ្យបានកាន់តែខ្លាំងក្លា និង ការអនុវត្តន៍អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ការពង្រឹងប្រព័ន្ធឆ្លើយតបទៅនឹងសេចក្តីរាយការណ៍អំពីអំពើហិង្សាពីមណ្ឌលថែទាំកុមារ បង្កើនការកាត់បន្ថយចំនួនកុមារនៅក្នុងមណ្ឌលថែទាំកុមារ ពង្រឹងអភិក្រមធ្វើសមាហរណកម្ម និងបង្កើនការយកចិត្តទុកដាក់ចំពោះកុមារពិការនៅក្នុងមណ្ឌលថែទាំកុមារ។

## ការឆ្លុះបញ្ចាំងរបស់អំពីការពិត ៖ កិច្ចការពារកុមារ

កម្មវិធី 3PCធ្វើប្រតិបត្តិការនៅក្នុងបរិយាកាសមួយដែលមានការលំបាកធ្ងន់ធ្ងរ ខ្លាំងនិង បរិយាកាសដែលកុមារកម្ពុជាទទួលរងអំពើហិង្សា។




កុមារ១នាក់ក្នុងចំណោមកុមារ២នាក់ បានទទួលរងការវាយដំធ្ងន់ធ្ងរ




កុមារី និងកុមារា១នាក់ក្នុងចំណោម ២០នាក់ អាយុក្រោម១៨ឆ្នាំ បានទទួលរងការប្រទូសកេរ្តិ៍ភេទ




កុមារ១នាក់ក្នុងចំណោមកុមារ៤នាក់ បានទទួលរងការរំលោភបំពានផ្លូវចិត្ត




ស្ត្រីចំនួន១៨% (អាយុចន្លោះពី២០-២៤ឆ្នាំ) បានរៀបការមុនអាយុ១៨ឆ្នាំ



កុមារ៩នាក់ក្នុងចំណោមកុមារ ១០០.០០០នាក់ កំពុងស្ថិតក្នុងការឃុំឃាំង



សេវាសង្គម ជាពិសេសគឺសេវាសម្រាប់កុមារដែលរងការរំលោភបំពាន និង កុមារក្រីក្រ នៅតែបន្តមានលក្ខណៈជាការផ្តល់សេវាចំពោះកិច្ចមានភាពបែកខ្ញែក និង មិនគ្រប់គ្រាន់។

ការដាក់កុមារនៅក្នុងមណ្ឌល បានឈានដល់កម្រិតមួយដ៏ខ្ពស់ ដោយមានកុមារសរុបចំនួន ១៦.៥៧៩នាក់ (៤៧%ជាកុមារី) អាយុក្រោម ១៨ឆ្នាំ កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ ចំនួន ៤០៦កន្លែង ទូទាំងប្រទេស ប៉ុន្តែ ក្នុងចំណោមកុមារទាំងនេះ មានកុមារ៣នាក់ ក្នុងចំណោមកុមារ៤នាក់ យ៉ាងហោចណាស់មានឪពុក ឬ ម្តាយម្នាក់ដែលនៅរស់។ ការទុកដាក់កុមារនៅក្នុងមណ្ឌល ធ្វើឱ្យកុមារកាន់តែមានការប្រឈមទៅនឹងអំពើហិង្សា ការកេងប្រវ័ញ្ច និង ការមិនអើពើ។





បុគ្គលិកសង្គមកិច្ចនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (មន្ទីរ សអយ) ខេត្តកណ្តាល ជាមួយគ្រួសាររបស់លោកស្រី មិច ដែលបានធ្វើការបង្រួបបង្រួមគ្រួសារដោយរីករាយ ក្រោយពេលដែលរដ្ឋាភិបាលបានទាក់ទងជាមួយមណ្ឌលថែទាំកុមារដែលកូនរបស់គាត់ម្នាក់រស់នៅទីនោះ ដើម្បីធ្វើការបង្រួបបង្រួម និង ធ្វើសមាហរណកម្មកុមារជាមួយគ្រួសាររបស់ពួកគេវិញ។

©UNICEF Cambodia/Sophea Phok

# ព័ត៌មានទំនាក់ទំនង

ទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
អគារលេខ ៧៨៨ មហាវិថីព្រះមុន្នីវង្ស
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ +៨៥៥ ២៣ ២១៤ ០៣៩

Email:mosvy.cwd@gmail.com

Website:mosvy.gov.kh